ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 13 / 02 / 2017
ម៉ោង (Time/Heure) : 12:00
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

002/19-09-2007-ECCC/TC
E1/511

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ចន្ទ ទី ១២ ខែ ធ្នូ ឆ្នាំ ២០១៦

## សវនាការលើភ័ស្តុតាង - ថ្ងៃ ៤៩១

រៀបចំដោយ៖ លោកស្រី សែ កុលវុឌ្ឍី និង លោក Harshan ATHURELIYA

| **កំណត់ហេតុអ្នកចូលរួម** |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តារ, ចៅក្រម Claudia FENZ |
| ចៅក្រមបំរុង៖ ចៅក្រម ធូ មណី, ចៅក្រម Martin KAROPKIN |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, លោក Harshan ATHURELIYA |
| ការិយាល័យសហព្រះរាជអាជ្ញា៖ កញ្ញា សុង ឆវ័ន្ត, លោក សេង លាង, លោក NicholasKOUMJIAN លោក Joseph Andrew BOYLE |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក Victor KOPPE, លោក លីវ សុវណ្ណា |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ អង្គ, លោកស្រី Marie GUIRAUD, លោក ឡោ ជុនធី, លោកស្រី ស៊ិន សុវ៉ន, លោក ហុង គីមសួន |

| |
|---|
| ដើមបណ្តឹង/សាក្សី/អ្នកជំនាញ៖ សាក្សី លោក នង នីម (2-TCW-1070) (ប្រព័ន្ធសោតទស្សន៍ពីខេត្តត្បូងឃ្មុំ), 2-TCW-823 (សាក្សីប្រភេទ ក) |
| មេធាវីប្រឹក្សាសាក្សី៖ លោក មឿន សុវណ្ណ (មេធាវីប្រឹក្សាសាក្សី 2-TCW-1070), លោក ចាន់ សម្បូរ (មេធាវីប្រឹក្សាសាក្សី 2-TCW-823) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោកស្រី អ៊ុច អារុណ |
| ផ្សេងៗ៖ កញ្ញា យស សេរីរត្ន័, លោក ឡុញ ង៉េត, លោក វ៉ាត សុម៉ៅ, កញ្ញា លី បូរ៉ានីន, កញ្ញា Anne-Catherine STANDAERT |

| **<u>ពេលវេលាទូទៅរបស់តុលាការ៖</u>** | | |
|---|---|---|
| ថ្ងៃទី ១២ ខែ ធ្នូ ឆ្នាំ ២០១៦ | ចាប់ផ្តើមម៉ោង៖ ០៩.០៦ | បញ្ចប់ម៉ោង៖ ១៦.០៧ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.១៥ | បញ្ចប់ម៉ោង៖ ១០.៣០ |
| សម្រាកពេលថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១១.៤៥ | បញ្ចប់ម៉ោង៖ ១៣.៣០ |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ ១៤.១០ | បញ្ចប់ម៉ោង៖ ១៤.៣០ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០៤ ម៉ោង និង ៤០ នាទី |

**<u>កិច្ចដំណើរការនីតិវិធីផ្សេងទៀត</u>**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ ក្រឡាបញ្ជី | ០៩.០៧ | ០៩.០៨ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្តី នួន ជា អង្គជំនុំជម្រះ | ០៩.០៨ | ០៩.១០ |
| សេចក្តីសម្រេចផ្ទាល់មាត់លើការទទួលយកឯកសារ E319/43.3.7 ជាឯកសារភ័ស្តុតាង | អង្គជំនុំជម្រះ | ០៩.១០ | ០៩.១៣ |
| សេចក្តីសម្រេចផ្ទាល់មាត់លើការទទួលយកឯកសារ E319/23.3.19.1 ជាឯកសារភ័ស្តុតាង | អង្គជំនុំជម្រះ | ០៩.១៣ | ០៩.១៥ |
| ការតាំងសំណួរទៅកាន់សាក្សី នង នីម | អង្គជំនុំជម្រះ | ០៩.១៦ | ០៩.២២ |

| | | | |
|---|---|---|---|
| (2-TCW-1070) | មេធាវីការពារក្តី នួន ជា<br>សហព្រះរាជអាជ្ញា<br><br>មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី | ០៩.២២<br>១១.២១<br>១៣.៣៣<br>១៣.៥៤ | ១១.១៩<br>១១.៤០<br>១៣.៥៤<br>១៤.០៧ |
| សេចក្តីសម្រេចផ្ទាល់មាត់លើការទទួលយកឯកសារទាក់ទងនឹងអ្នកជំនាញ 2-TCE-1062 | អង្គជំនុំជម្រះ | ១១.៤០ | ១១.៤៣ |
| ការកត់សម្គាល់របស់មេធាវីការពារក្តី នួន ជា ពាក់ព័ន្ធនឹងឯកសាររបស់សាស្ត្រាចារ្យ Heynowski | មេធាវីការពារក្តី នួន ជា | ១៣.៣២ | ១៣.៣៣ |
| ការតាំងសំណួរទៅសាក្សី 2-TCW-823 (សាក្សីប្រភេទ ក) | អង្គជំនុំជម្រះ<br>សហព្រះរាជអាជ្ញា<br>មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី | ១៤.៣៦<br>១៤.៤៥<br>១៥.៥២ | ១៤.៤៤<br>១៥.៥២<br>១៦.០៥ |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការនិងការប្រកាសពីវត្តមានរបស់ភាគី</u>**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន។ ជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

**<u>សំណើរបស់ នួន ជា សុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ</u>**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឱ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

**<u>សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តី ខៀវ សំផន អនុលោមតាមវិធាន ៨៧(៣) និង (៤) ស្នើសុំឱ្យទទួលយកឯកសារ E319/43.3.7 ជាឯកសារភ័ស្តុតាង</u>**

អង្គជំនុំជម្រះកត់សម្គាល់ថានៅថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៦ មេធាវីការពារក្តី ខៀវ សំផន បានជូនដំណឹងមកអង្គជំនុំជម្រះថា ខ្លួនយល់ថាឯកសារ E319/43.3.7 មានភាពពាក់ព័ន្ធទៅនឹងការតាំងសំណួរទៅកាន់

សាក្សីដែលនឹងត្រូវមកផ្តល់សក្ខីកម្ម គឺសាក្សីដែលមានរហស្សនាម 2-TCW-823 ហើយបានស្នើសុំឱ្យទទួលយកឯកសារនេះជាឯកសារភ័ស្តុតាងអនុលោមតាមវិធាន ៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង។ បន្ទាប់ពីបានស្តាប់ សារណាផ្ទាល់មាត់របស់ភាគីនានាលើបញ្ហានេះ កាលពីថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១៦ ដោយកត់សម្គាល់ថា មិនមានភាគីណាមួយជំទាស់ទៅនឹងសំណើនេះទេ ហើយនិងកត់សម្គាល់ពីលក្ខណ្ឌតម្រូវនៃវិធាន ៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះពិចារណាឃើញថាឯកសារនេះបំពេញតាមលក្ខណ្ឌតម្រូវនៃវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ហើយទទួលយកឯកសារនេះជាឯកសារភ័ស្តុតាង។ អង្គជំនុំជម្រះកំណត់លេខឯកសារ E319/43.3.7 ទៅជាលេខ E3/10768 ។

<u>សេចក្តីសម្រេចផ្ទាល់មាត់ទៅលើឯកសារ E319/23.3.19.1 ទាក់ទិននឹងសាក្សីដែលមានរហស្សនាម 2-TCW-823</u>

កាលពីថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៦ ក្រុមមេធាវីការពារក្តី ខៀវ សំផន បានជូនដំណឹងមកអង្គជំនុំជម្រះតាមរយៈអ៊ីម៉ែលថា ក្រុមរបស់ខ្លួនមានបំណងស្នើសុំឱ្យអង្គជំនុំជម្រះទទួលយកឯកសារ E319/23.3.19.1 ដែលទាក់ទងនឹងសាក្សី 2-TCW-823 ជាឯកសារភ័ស្តុតាង។ ឯកសារនេះមានសេចក្តីដកស្រង់កិច្ចសម្ភាសន៍របស់សាក្សីជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជានៅក្នុងឆ្នាំ ២០០៧ (ឯកសារ E3/9069) ដោយមានការកែតម្រូវជាសំណេរផ្ទាល់ដៃមួយចំនួនដែលសាក្សីបានធ្វើឡើង ក្នុងអំឡុងពេលបន្តបន្ទាប់ ដែលគាត់ផ្តល់ចម្លើយដល់ការិយាល័យសហចៅក្រមស៊ើបអង្កេត។ អង្គជំនុំជម្រះសម្រេចទទួលយកឯកសារ E319/23.3.19.1 ជាឯកសារភ័ស្តុតាង ដោយសារតែឯកសារនេះជាចម្លើយពីមុនរបស់សាក្សី និងដាក់លេខសម្គាល់ជាឯកសារ E3/9817A។

<u>ការតាំងសំណួរទៅសាក្សី នង នឹម (2-TCW-1070)</u>

អង្គជំនុំជម្រះបានសួរសំណួរបឋម និងបានប្រាប់ពីសិទ្ធិ និងករណីកិច្ច និងកាតព្វកិច្ចដល់សាក្សីបន្ទាប់មក មេធាវីការពារក្តី នួន ជា សហព្រះរាជអាជ្ញា មេធាវីនាំមុខតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី បានតាំងសំណួរទៅសាក្សី (2-TCW-1070) តាមរយៈប្រព័ន្ធសោតទស្សន៍ពីខេត្ត ត្បូងឃ្មុំ។

<u>សេចក្តីសម្រេចផ្ទាល់មាត់លើសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យទទួលយកឯកសារចំនួន ៣ ធ្វើជាឯកសារភ័ស្តុតាង</u>

នៅថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៦ សហព្រះរាជអាជ្ញាបានស្នើឱ្យអង្គជំនុំជម្រះទទួលយកឯកសារចំនួន ៣ អនុលោមតាមវិធាន ៨៧.៤ នៃវិធានផ្ទៃក្នុង ដែលទាក់ទងនឹងអ្នកជំនាញ 2-TCE-1062។ មិនមានភាគីណាមួយជំទាស់ទៅនឹងសំណើសុំនេះទេ។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចទទួលយកឯកសារទាំងបីនោះធ្វើជាឯកសារភ័ស្តុតាង និងដាក់លេខសម្គាល់ E3/10765 ចំពោះឯកសារទី១, E3/10766

ចំពោះឯកសារទី២ និង E3/10767 ចំពោះឯកសារទី៣។

<u>ការតាំងសំណួរទៅសាក្សី 2-TCW-823 (សាក្សីប្រភេទ ក)</u>

អង្គជំនុំជម្រះបានតាំងសំណួរបឋមមួយចំនួន ព្រមទាំងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចដល់សាក្សី បន្ទាប់មកសហព្រះរាជអាជ្ញា មេធាវីនាំមុខតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណី បានតាំងសំណួរទៅសាក្សី 2-TCW-823។

## Newly Admitted Documents

| *TC No* | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/9817A | E319/23.3.19.1 | 01033983-01033990<br>01313339-01313344<br>01308956-01308964 | [Corrected 1] DC-Cam Interview of [REDACTED] | C | 01033988 | 01313342 | 01308961 |
| E3/10768 | E319/43.3.7 | 01138455-01138488<br>01170528-01170551 | Written Record of Interview of witness [REDACTED] | C | / | / | / |
| E3/10765 | | 01319488-01319491<br>01336753-01336755<br>01336756-01336758 | The Report on the Preservation of the Remains of the Victims at Choeung Ek Genocidal Center | P | / | / | / |
| E3/10766 | | 01319492-01319493<br>01336759-01336760<br>01336761-01336764 | The charts titled Exhausted list of Preserved remains and list of Marks of Torture and Marks of Execution | P | / | / | / |
| E3/10767 | | 01319494-01319515<br>01336765-01336791<br>01336792-01336810 | The transcript of the interview of Him Huy conducted on 9 August 2014 | P | / | / | / |

## Reclassified Document

| *TC No* | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/10717 | / | 01340440-01340530<br>01355695-01355824<br>01348485-01348572 | [Corrected 2] DC-Cam's interview with Nong Nim | P | 01340486<br>01340510<br>01340476<br>01340483<br>01340497<br>01340495<br>01340497<br>01340508<br>01340505<br>01340522<br>01340524<br>01340501 | p. 67 (ERN 01355761)<br>101 (ERN 01355795)<br>pp 52-53 (ERN 01355746-01355747)<br>p. 63 (ERN 01355757)<br>p. 62 (ERN 01355756)<br>p. 82 (ERN 01355776)<br>p. 80 (ERN 01355774)<br>p. 83 (ERN 01355777)<br>p. 94 (ERN 01355788)<br>01348551,<br>01355792<br>01355814<br>01355816<br>01355783<br>01355782 | 01348530<br>01348553<br>01348519<br>01348520<br>01348527<br>01348526<br>01348540<br>01348539<br>01348541<br>01348551<br>01348548<br>01348565<br>01348567<br>01348545<br>01348544 |
| E3/517 | D234/10 | 00373439-00373445<br>00375878-00375884<br>00426346-00426352 | Written Record of Interview of LOEK São | P | 00373441 | 00375880 | 00426348 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/3259 | D313/1.2.203 | P00416559 | Photograph depicting senior leaders meeting a delegation | P | | P00416559 | |
| E3/10665 | F2/9.2 | 01168433-01168486 01156796-01156827 | Annex 2: Interviews of TOAT Thoeun with THET Sambath and Robert LEMKIN, 21 October 2015 | P | 01168480 | 01156823 | / |
| E3/9675 | | 00955532-00955541 00977710-00977718 01104060-01104067 | Written Record of Interview of PAK Sok Dated 19-10-2013 | P | 00955535 | 00977713 | 01104062 01104063 |

## Other Documents (No Change)

| *TC No* | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/1593 | / | 00637356-00638099 01149978-01150245 00638722-00638099 | [Corrected 1] Book by Ben Kiernan entitled "The Pol Pot Regime: Race, Power, and Genocide in Cambodia under the Khmer Rouge, 1975-79 | P | 00637947 | 01150203 | 00639172 |
| E3/9817 | E319/23.3.19 | 01033991-01033997 01040413-01040418 01362309-01362313 | Written Record of Interview of [redacted] dated 20-10-2014 | C | 01033991 | 01040414 | 01362309 |
| E3/9069 | E305/13.23.361 | 00926295-00926339 00969918-00969958 | Statement of [redacted] (DC-Cam) | C | 00926305 00926311 00926312 00926338 00926328 | 00969927 00969934 00969935 00969957 00969958 00969949 | / |
| E3/10604 | E393.2 | 01222328-01222936 | Annex 2: OCIJ S-21 Prisoners List 31 March 2016 | P | / | 01222426 | / |

| | | | | | | | |
|---|---|---|---|---|---|---|---|
| F1/3.1 | / | 01116540-01116644 01116406-01116539 01118488-01118632 | Transcript of appeal hearing in Case 002/01 - 06 July 2015 | P | / | / | / |
| E3/9610 | E319.1.27/ D118/102 | 00947574-00947613 00974011-00974052 00974702-00974737 | Written record of witness interview [REDACTED] | C | / | 00974017 | 00974707 |
| E3/3015R | | V00422521 | DDC_VI_001248 Pol Pot visiting a rubber tree plantation and Khmer Rouge soldiers preparing for war | P | 01:53 + 10 Sec | | |

**ដីកា/សេចក្ដីសម្រេចផ្ទាល់មាត់៖**

- អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ (០៩.១០)
- សេចក្ដីសម្រេចផ្ទាល់មាត់លើសំណើសុំរបស់មេធាវីការពារក្ដី ខៀវ សំផន ក្នុងការទទួលយកឯកសារ E319/43.3.7 ជាឯកសារភ័ស្ដុតាងហើយ ដាក់លេខសំគាល់ E3/10768A។ (០៩.១២)
- សេចក្ដីសម្រេចផ្ទាល់មាត់លើសំណើសុំរបស់មេធាវីការពារក្ដី ខៀវ សំផន ក្នុងការទទួលយកឯកសារ E319/23.3.19.1 ជាឯកសារភ័ស្ដុតាង ហើយដាក់លេខសំគាល់ E3/9817A។ (០៩.១៥)
- សេចក្ដីសម្រេចផ្ទាល់មាត់លើសំណើសុំរបស់សហព្រះរាជអាជ្ញា ក្នុងការទទួលយកឯកសារចំនួន ៣ ជាឯកសារភ័ស្ដុតាង។ (១១.៤៣)
- អង្គជំនុំជម្រះសម្រេចថា សាក្សីប្រភេទ ក ជាវិធានការការពារសម្រាប់សាក្សី 2-TCW-823 ដែលជាវិធានការសមស្របតាមច្បាប់។ (១៤.៣២)
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំ

| |
|---|
| ឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញឱ្យបានមុនម៉ោង ៩.០០ ព្រឹកនៅថ្ងៃ អង្គារ៍ ទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៦។ (១៦.០៦) |

| **កាលវេលាសវនាការបន្ត** |
|---|
| សវនាការនឹងបន្តទៅថ្ងៃអង្គារ៍ ទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៦ ចាប់ផ្តើមពីម៉ោង ០៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃ... ២០១៦

ក្រឡាបញ្ជី ... ក្រឡាបញ្ជី

លោកស្រី សែ គុលឧត្តរា ... លោក Harshan ATHURELIYA